# កិច្ចព្រមព្រៀង

## រវាង

## រាជរដ្ឋាភិបាលកម្ពុជា

## និង

## រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

## ស្តីពី

## កិច្ចសហប្រតិបត្តិការបច្ចេកទេស

ឆ្នាំ២០១៣

# រាជរដ្ឋាភិបាលកម្ពុជា
# និង
# រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

ក្នុងស្មារតីទំនាក់ទំនងជាមិត្តភាពដែលមានកន្លងមករវាង ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ក្នុងបំណងពង្រឹង និងរឹតចំណងមិត្តភាពតាមរយៈកិច្ចសហប្រតិបត្តិការបច្ចេកទេស ក្នុងស្មារតីភាពជាដៃគូ កិច្ចព្រមព្រៀងនេះបង្កើតជាមូលដ្ឋានគ្រឹះនៃការថែរក្សាទំនាក់ទំនងនោះ ក្នុងគោលបំណងដើម្បីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា យោងតាមកំណត់ហេតុកិច្ចចរចារវាងរដ្ឋាភិបាលទាំងពីរនៅទីក្រុងភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៣ និងអនុលោមតាមកិច្ចព្រមព្រៀងចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៩៤, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៧, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១០, ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១២ និងថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣

បានព្រមព្រៀងដូចខាងក្រោមៈ

## មាត្រា ១

(១) អនុលោមតាមកិច្ចព្រមព្រៀងថ្ងៃទី ០៦ ខែឧសភា ឆ្នាំ១៩៩៤ រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេស គម្រោងនានាខាងក្រោមនេះត្រូវបានជម្រុញសម្រាប់ការអនុវត្ត ៖

១- កំណែទម្រង់រដ្ឋបាល និងវិមជ្ឈការ ដំណាក់កាលទី ៤ (Administrative Reform and Decentralization IV)

២- ការទទួលបានយុត្តិធម៌របស់ស្ត្រី ដំណាក់កាលទី ២ (Access to Justice for Women II)

៣- កម្មវិធីស្តីពីការគាំពារសុខភាពសង្គម ដំណាក់កាលទី ២ (Programme on Social Health Protection II)

៤- កម្មវិធីស្តីពីការគាំពារសុខភាពសង្គម ដំណាក់កាលទី ៣ (Programme on Social Health Protection III)

៥- សុខភាពមាតា និងទារក (Mother and Child Health)

៦- កម្មវិធីស្តីពីសិទ្ធិលើដីធ្លី ដំណាក់កាលទី ២ (Land Rights Programme II)

៧- ការអភិវឌ្ឍសេដ្ឋកិច្ចថ្នាក់មូលដ្ឋាន ដំណាក់កាលទី ៣ (Regional Economic Development III)

៨- ហិរញ្ញប្បទានសម្រាប់ការសិក្សា និងជំនាញការ (Study and Expert Fund)

ប្រសិនបើការសិក្សាបានរកឃើញថាគម្រោងទាំងនេះមានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់ជម្រុញការអនុវត្ត ។

(២) សម្រាប់គម្រោងទាំងឡាយដែលបានចែងក្នុងកថាខ័ណ្ឌ (១) ខាងលើ រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ នឹងផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការផ្ទាល់របស់ខ្លួនសរុបចំនួន **២៤,០៥០,០០០ អឺរ៉ូ** (ម្ភៃបួនលានប្រាំម៉ឺនអឺរ៉ូ) ក្រោមទម្រង់ជា បុគ្គលិក ធាតុចូល និងវិភាគទានហិរញ្ញវត្ថុសមស្រប ។ Deutsche Gesellschaft Für Internationale Zusammenarbeit (GIZ) GmbH ជាអង្គភាពទទួលបន្ទុកអនុវត្តគម្រោងទាំងឡាយដូចមានចែងក្នុងកថាខ័ណ្ឌ (១) ខាងលើ ។

(៣) រាជរដ្ឋាភិបាលកម្ពុជាត្រូវធានាថាគម្រោងនីមួយៗមានខ្ទង់ថវិកាផ្ទាល់របស់ខ្លួន ដើម្បីឱ្យ ការអនុវត្តដំណើរការបានយ៉ាងរលូន និងត្រូវធានាឱ្យបានថាស្ថាប័នទទួលបន្ទុកការអនុវត្តនឹងផ្តល់នូវការគាំទ្រចាំបាច់នានា សម្រាប់គម្រោងទាំងឡាយដែលបានចែងនៅក្នុងកថាខ័ណ្ឌ (១) ខាងលើ ។

(៤) គម្រោងទាំងឡាយដែលបានចែងនៅក្នុងកថាខ័ណ្ឌ (១) ១-៨ ខាងលើអាចជំនួសដោយគម្រោងផ្សេងៗទៀតបានដោយមានការឯកភាពគ្នារវាង រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងរាជរដ្ឋាភិបាលកម្ពុជា ។

(៥) ការសន្យាផ្តល់សម្រាប់គម្រោងដែលបានចែងក្នុងកថាខ័ណ្ឌ (១) ១-៨ ខាងលើ និងចំនួនហិរញ្ញប្បទានសហ-ប្រតិបត្តិការបច្ចេកទេសដែលបានចែងក្នុងកថាខ័ណ្ឌ (២) ខាងលើ នឹងត្រូវអស់សុពលភាពក្នុងការអនុវត្តដោយមិនមានការជំនួសអ្វីទាំងអស់ ប្រសិនបើ កិច្ចព្រមព្រៀងអនុវត្តគម្រោងនិងកិច្ចព្រមព្រៀងហិរញ្ញប្បទានទាំងឡាយមិនត្រូវបានអនុវត្ត ដោយផ្អែកតាមមាត្រាទី២នៃកិច្ចព្រមព្រៀងនេះ ក្នុងរយៈពេលប្រាំពីរឆ្នាំ បន្ទាប់ពីឆ្នាំដែលការសន្យាបានធ្វើឡើង ។ដោយមិនមានការរំលោភដល់ខ្លឹមសារដែលបានចែងក្នុងកថាខ័ណ្ឌ(៤)ខាងលើ កាលបរិច្ឆេទផុតកំណត់សម្រាប់ការសន្យាដែលបានធ្វើឡើងក្នុងឆ្នាំនេះ ត្រូវមានសុពលភាពត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ។ ប្រសិនបើ ស្ថិតក្នុងពេលវេលាកំណត់នេះ កិច្ចព្រមព្រៀងអនុវត្តគម្រោងនិងកិច្ចព្រមព្រៀងហិរញ្ញប្បទាននានា ត្រូវបានធ្វើឡើងតែមួយផ្នែកនៃការសន្យា ការលុបចោលត្រូវអនុវត្តចំពោះតែចំនួនដែលនៅសល់ប៉ុណ្ណោះ មិនគ្របដណ្តប់ទៅលើកិច្ចព្រមព្រៀងទាំងមូលឡើយ ។

## មាត្រា ២

សេចក្តីលម្អិតនៃគម្រោងនិមួយៗដែលមានចែងក្នុងមាត្រា ១ (១) នៃកិច្ចព្រមព្រៀងនេះ រួមជាមួយនឹងសេចក្តីលម្អិតនៃវិភាគទាននិងកាតព្វកិច្ចទាំងឡាយ ត្រូវរៀបរាប់នៅក្នុងកិច្ចព្រមព្រៀងអនុវត្តគម្រោងនិងកិច្ចព្រមព្រៀងហិរញ្ញប្ប-ទាន ដោយឡែកៗពីគ្នា ដែលត្រូវបានកំណត់ដោយស្ថាប័នទទួលបន្ទុកអនុវត្តគម្រោងផ្អែកតាមមាត្រា ១ (២) និង

(៣) នៃ កិច្ចព្រមព្រៀងនេះ ។ កិច្ចព្រមព្រៀងអនុវត្តគម្រោង និងកិច្ចព្រមព្រៀងហិរញ្ញប្បទានទាំងនេះត្រូវស្ថិតនៅក្រោមអំណាចនៃច្បាប់ និងលិខិតបទដ្ឋាន នានារបស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ។

## មាត្រា ៣

(១) រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកបង់ពន្ធសម្រាប់ការនាំចូលសម្ភារៈបរិក្ខារ យានយន្ត និងគ្រឿងបន្លាស់ សម្រាប់ការអនុវត្តគម្រោងផ្អែកលើមាត្រា១ (១) នៃកិច្ចព្រមព្រៀងនេះ និងការចំណាយក្នុងនាមរបស់រដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ទៅលើ អាជ្ញាប័ណ្ណ ពន្ធគយ ពន្ធនាំចូល ពន្ធនាំចេញ និងការបង់ថ្លៃសម្រាប់សេវាសាធារណៈផ្សេងៗ រួមទាំងថ្លៃឈ្នួលឃ្លាំង និងត្រូវធានាថាការបំពេញបែបបទគយត្រូវដំណើរការដោយគ្មានការយឺតយ៉ាវឡើយ ។

(២) រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវធានាបង់ពន្ធ និងអាករជាបន្ទុករបស់រដ្ឋនូវថ្លៃសេវាសាធារណៈទាំងអស់ដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាជំនួសឱ្យ GIZ ដូចមានចែងនៅក្នុងមាត្រា២នៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា ៤

(១) ហិរញ្ញប្បទានចំនួន ១០១,០៣៨.៣៧ អឺរ៉ូ (មួយសែនមួយពាន់សាមសិបប្រាំបីអឺរ៉ូនិងសាមសិបប្រាំពីរសេន) ដែលបានអនុម័តឱ្យប្រើប្រាស់ក្នុងគម្រោងកំណែទម្រង់វិស័យសុខាភិបាលដែលមានចែងក្នុងមាត្រា ១ (១) ៥ នៃកិច្ចព្រមព្រៀងសហប្រតិបត្តិការបច្ចេកទេស ឆ្នាំ២០០៥ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៧ នឹងត្រូវផ្ទេរការប្រើប្រាស់ ។

(២) ហិរញ្ញប្បទានចំនួន ៧៤,០៤៩.៨៧ អឺរ៉ូ (ប្រាំពីរម៉ឺនបួនពាន់សែសិបប្រាំបួនអឺរ៉ូនិងប៉ែតសិបប្រាំពីរសេន) ដែលបានអនុម័តឱ្យប្រើប្រាស់ក្នុង គម្រោងសមភាពយេនឌ័រនិងសិទ្ធរបស់ស្ត្រី ដែលមានចែងក្នុងមាត្រា ១ (១) ៦ នៃកិច្ចព្រមព្រៀងសហប្រតិបត្តិការបច្ចេកទេស ឆ្នាំ២០០៥ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៧ នឹងត្រូវផ្ទេរការប្រើប្រាស់ ។

(៣) ហិរញ្ញប្បទានចំនួន ២១,៤១២.២១ អឺរ៉ូ (ពីរម៉ឺនមួយពាន់បួនរយដប់ពីរអឺរ៉ូនិងម្ភៃមួយសេន) ដែលបានអនុម័តឱ្យប្រើប្រាស់ក្នុងគម្រោងកំណត់អត្តសញ្ញាណជនក្រីក្រដែលមានចែងក្នុងមាត្រា ១ (១) ៣ នៃកិច្ចព្រមព្រៀងសហប្រតិបត្តិការបច្ចេកទេស ឆ្នាំ២០០៥ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៧ នឹងត្រូវធ្វើការផ្ទេរការប្រើប្រាស់ ។

(៤) ហិរញ្ញប្បទានចំនួនសរុប ១៩៦,៥០០.៤៥ អឺរ៉ូ (មួយសែនប្រាំបួនម៉ឺនប្រាំមួយពាន់ប្រាំរយអឺរ៉ូនិងសែសិបប្រាំសេន) នឹងត្រូវបានផ្ទេរជាហិរញ្ញប្បទានបន្ថែមសម្រាប់ប្រើប្រាស់ក្នុងគម្រោង ការទទួលបានយុត្តិធម៌របស់ស្ត្រី ដោយផ្អែកតាមមាត្រា១ (១) ៤ នៃកិច្ចព្រមព្រៀងសហប្រតិបត្តិការបច្ចេកទេស សម្រាប់ឆ្នាំ២០០៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១០ ។

យោងតាមមាត្រា ១ (៥) នៃកិច្ចព្រមព្រៀងសហប្រតិបត្តិការបច្ចេកទេស សម្រាប់ឆ្នាំ ២០០៥ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៧ ការសន្យាផ្តល់ហិរញ្ញប្បទាននេះនឹងត្រូវអស់សុពលភាព ប្រសិនបើកិច្ច ព្រមព្រៀងអនុវត្តគម្រោង និងកិច្ចព្រមព្រៀងហិរញ្ញប្បទានទាំងឡាយមិនបានចុះហត្ថលេខា ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ។

## មាត្រា ៥

ដោយផ្អែកតាមមាត្រា ១ (១) ខាងលើ រាល់លក្ខខណ្ឌដែលចែងនៅក្នុងកិច្ចព្រមព្រៀង ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ ១៩៩៤ ស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេស នឹងត្រូវយកមកអនុវត្តចំពោះកិច្ចព្រមព្រៀងបច្ចុប្បន្ននេះ ។

## មាត្រា ៦

កិច្ចព្រមព្រៀងនេះនឹងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ ២០១៤ មាន ២ ច្បាប់ដើម ចម្លងជាបីភាសាគឺ ភាសាខ្មែរ អាល្លឺម៉ង់ និង អង់គ្លេស អត្ថបទទាំង ៣ ភាសានេះមានតំលៃដូចគ្នា ។ ក្នុងករណីការបកប្រែមិនស្របមតិគ្នារវាងអត្ថបទ ភាសាខ្មែរ និងអាល្លឺម៉ង់ នោះអត្ថបទភាសាអង់គ្លេសនឹងត្រូវទុកជាបានការ ។

**តំណាង**
**រាជរដ្ឋាភិបាលកម្ពុជា**

**តំណាងរដ្ឋាភិបាល**
**សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់**